**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ:** ១០៤៤ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ** : ករណីស្តីពីលទ្ធផលនៃកិច្ចប្រជុំ ស្តីពីបញ្ហាតំបន់ ៣ ជុំវិញទន្លេសាប ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ។
**យោង** : - លិខិតលេខ ៣៦០ ក.ក.ជ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។
- ចំណារសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា : រាជរដ្ឋាភិបាលបានឯកភាពលើលទ្ធផលនៃកិច្ចប្រជុំ ស្តីពីបញ្ហាតំបន់ ៣ ជុំវិញទន្លេសាប ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ដូចខាងក្រោម ÷

១- ការដោះស្រាយដីបង្កបង្កើនផលនៅតំបន់ ៣ ជូនប្រជាជន ត្រូវឈរលើឯកសារលិខិតបទដ្ឋានគតិយុត្តិនិងបទបញ្ជានានារបស់រាជរដ្ឋាភិបាល ក្នុងនោះការផ្តល់ដីធ្វើស្រែនៅក្នុងតំបន់ ៣ ជូនប្រជាជនត្រូវពិនិត្យឱ្យបានហ្មត់ចត់ គឺជាដីអាស្រ័យផលពិតប្រាកដ ហើយប្រជាពលរដ្ឋដែលរស់នៅទីនោះមានការទទួលស្គាល់ពីអាជ្ញាធរភូមិ-ឃុំ។ ដីធ្វើស្រែនៅក្នុងតំបន់ ៣ ដែលបានឃ្មៀលជូនប្រជាជន មិនមែនជាដីកម្មសិទ្ធទេ តែប្រជាជនអាចមានសិទ្ធិកាន់កាប់អាស្រ័យផល តែមិនមានសិទ្ធិចាត់ចែង។

២- រាល់ការស្នើសុំដី ឬឃ្មៀលដីអាស្រ័យផលជូនប្រជាជន ត្រូវមានផែនទីបញ្ជាក់ទីតាំងនិងនិយាមកាច្បាស់លាស់។

៣- ពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវចំណាររបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១២ លើសំណើរបស់ក្រសួងធនធានទឹកនិងឧតុនិយម ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១២ ក្នុងការបែងចែកដីជូនប្រជាជនចំនួន ៤.០០៤គ្រួសារ នៅក្នុងឃុំ ៦ ស្រុកស្ទោង ខេត្តកំពង់ធំ។

៤- រាល់ដីបង្កបង្កើនផលនៅក្នុងតំបន់ ៣ ដែលជាការវិនិយោគធ្វើអាជីវកម្ម មិនត្រូវអនុញ្ញាតឱ្យធ្វើអាជីវកម្មទេ ហើយការអនុវត្តខ្លឹមសារនេះនឹងត្រូវអនុវត្តដូចបណ្តាខេត្តពាក់ព័ន្ធនានាជុំវិញបឹងទន្លេសាប គឺមានខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងខេត្ត កំពង់ធំ។

៥- ត្រូវបង្កើតក្រុមការងារបច្ចេកទេសមួយដែលដឹកនាំដោយអាជ្ញាធរទន្លេសាប និងមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ សហការជាមួយនឹងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពង់ធំ និងគណៈបញ្ជាការឯកភាពខេត្ត-ស្រុក ដើម្បីចុះសិក្សា-ត្រួតពិនិត្យឱ្យបានច្បាស់លាស់ក្នុងការឃៀល និងបែងចែកដីអាស្រ័យផលក្នុងតំបន់ ៣ ជូនប្រជាជននៅក្នុងភូមិ-ឃុំដែលពាក់ព័ន្ធ និងធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីលើកសំណើជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ពិនិត្យ និងសម្រេច។

៦- ដីនៅក្នុងតំបន់ ២ អាចធ្វើស្រែបង្កបង្កើនផលបាន តែបើមានព្រៃលិចទឹកនៅក្នុងតំបន់ ២ ប្រជាពលរដ្ឋត្រូវជួយថែរក្សាទុក ដោយឡែកប្រសិនបើមានការសាងសង់ទំនប់ប្រឡាយសហគមន៍និងអាជ្ញាធរមូលដ្ឋាន ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងធនធានទឹកនិងឧតុនិយមជាមុន។

៧- ក្រសួងធនធានទឹកនិងឧតុនិយមត្រូវរៀបចំបោះបង្គោលកំណត់តំបន់ ៣ ឱ្យបានញឹកបន្តិចអាចឃ្លាតពីបង្គោលមួយទៅបង្គោលមួយប្រវែង ៥០០ម៉ែត្រ ដើម្បីឱ្យប្រជាជនងាយយល់ដឹងពីព្រំប្រទល់តំបន់ ៣ និងតំបន់ ២ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៊ុន-អ៊ុយ

<u>**ចម្លងជូន**</u> ÷
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកឧត្តមមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ឯកឧត្តមអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលជលផល
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
  នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន
- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន**
- ឯកសារ - កាលប្បវត្តិ